# ជយោ ភាសាខ្មែរ!

•

ផ្សាយចេញពីគណៈកម្មាធិការអចិន្ត្រៃយ៍ នៃសមាគមចំរុះ

ភ្នំពេញ 1967

- សេចក្ដីថ្លែងការណ៍រួម នៃសមាគមទាំងដប់ . . . 9
- អំពីខេមរនីយកម្ម . . . 27
- កំណត់ហេតុ . . . 49
- ដកស្រង់ពាក្យដែលប្រែហើយ . . . 60

# ជយោ ភាសាខ្មែរ !

•

ផ្សាយចេញពីគណៈកម្មាធិការអចិន្ត្រៃយ៍ នៃសមាគមចំរុះ
ភ្នំពេញ 1967

«ជាមួយនឹងឯករាជ្យជាតិ ភាសាជាតិត្រូវមាននាទី
ដ៏ធំ ហើយបំពេញមុខងារដ៏ខ្ពង់ខ្ពស់ ។ ខ្មែរយើង
ក៏បានរៀបចំភាសាជាតិ ឱ្យទៅជាឧបករណ៍សំរាប់
ប្រើឱ្យសមទៅតាមការចាំបាច់នៃឯករាជ្យជាតិ ។»

សម្ដេចព្រះ នរោត្ដម សីហនុ

*ក្នុងពិធីថ្វាយសញ្ញាបត្របណ្ឌិតខាងអក្សរសាស្ត្រ*

*ចំពោះសម្ដេចព្រះសង្ឃរាជថ្នាក់ទី ១*

«ការយកភាសាជាតិមកប្រើជាផ្លូវការ គឺជាការចាំបាច់» ។

សេចក្តីថ្លែងការណ៍រួម — 5-7-67

---

ចំពោះមិត្តសមាជិកសមាគមទាំងអស់

គណៈកម្មាធិការអចិន្ត្រៃយ៍ នៃសមាគមចំរុះ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះសមាគមទាំងឡាយ ដែលបានផ្តល់វិភាគទានដ៏សប្បុរសរបស់ខ្លួន សំរាប់បោះពុម្ពកំរងអត្ថបទនេះ ។ ការបោះពុម្ពនេះយឺតយូរបន្តិច មកពីគណៈកម្មាធិការអចិន្ត្រៃយ៍ នៅរង់ចាំមើលវិភាគទានរបស់មិត្តសមាគមនីមួយ ៗ ដើម្បីនឹងសំរេចថា តើត្រូវបោះពុម្ពតាមប៉ុណ្ណា ឬ បោះពុម្ពដូចនេះ ។ សូមអភ័យទោស ។

គណៈកម្មាធិការអចិន្ត្រៃយ៍

ការបោះផ្សាយនេះសំរេចឡើង ដោយ
វិភាគទានដ៏សប្បុរស នៃសមាគមខាងក្រោមនេះ

| | | |
|---|---|---|
| 1. | សមាគម សាធារណការ | 3 000 ៛ |
| 2. | សមាគម បុគ្គលិកសិក្សាខ្មែរ | 2 000 ៛ |
| 3. | សមាគម កម្ពុជបុត្រ | 1 500 ៛ |
| 4. | សមាគម សាស្ត្រាចារ្យខ្មែរ | 1 000 ៛ |
| 5. | សមាគម ផ្លូវរថភ្លើង | 1 000 ៛ |
| 6. | សមាគម ទូទៅនៃនិស្សិតខ្មែរ ប្រទេសកម្ពុជា | 1 000 ៛ |
| 7. | សមាគម ចំរើនវិជ្ជា | 1 000 ៛ |
| 8. | សមាគម វិចិត្រសិល្បករខ្មែរ | 500 ៛ |
| 9. | សមាគម សង្គ្រោះបុគ្គលិកសាធារណការ | 200 ៛ |
| 10. | សមាគម សិស្សចាស់នៃអនុវិទ្យាល័យ នឹងវិទ្យាល័យព្រះស៊ីសុវត្ថិ | |

«ការប្រើភាសាខ្មែរជាផ្លូវការ នឹងនាំឱ្យ សាមគ្គីភាព រវាងពលរដ្ឋខ្មែរគ្រប់ជាន់ថ្នាក់ មានកំរិតកាន់តែខ្ពស់ ឡើងទៀត ។»

«ការប្រើភាសាខ្មែរជាផ្លូវការ ពិតជាឆ្លើយតបទៅនឹង សេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ នឹងសេចក្ដីត្រូវការ របស់ស្ថានការណ៍ពន់ពេកណាស់ ។»

សេចក្ដីថ្លែងការណ៍រួម – 5.7.67

# សេចក្ដីថ្លែងការណ៍រួម៖

## សេចក្ដីបង្ហាញ

ប្រជាជាតិយើង ដែលបានសំរេចមហាជោគជ័យក្នុងឯករាជ្យនយោបាយកាលពីឆ្នាំ១៩៥៣ បានសំរេចជោគជ័យថ្មីមួយទៀតក្នុងឯករាជ្យសេដ្ឋកិច្ចកាលពីឆ្នាំ១៩៦៣ ។ ថ្មីៗនេះ ក្នុងសមាជជាតិទី២៣ មហាជនក្នុងមជ្ឈដ្ឋាននានា សមាគមនានា ទីផ្សារជននានាបានបញ្ចេញសំលេងជាឯកច្ឆន្ទស្នើយកភាសាជាតិមកប្រើជាផ្លូវការ ហើយប្រើជាភាសាយានក្នុងការសិក្សា ។ ក្នុងឱកាសនោះ សមាគមយើងទាំងដប់ ដែលបានប្រជុំគ្នាជាមហាសន្និបាតវិសាមញ្ញ ក៏បានចាត់តំណាងឲ្យឡើងទៅបញ្ជាក់ជំហរ ហើយស្នើយោបល់និងគំរោងការរបស់ខ្លួនចំពោះបញ្ហានេះដែរ ។ តាមព្រះបញ្ញាដ៏ភ្លឺវៃនៃសម្ដេចសហជីវិន សមាជជាតិក៏បានអនុម័តសេចក្ដីស្នើដ៏ត្រឹមត្រូវរបស់មហាជនគ្រប់មជ្ឈដ្ឋានខាងលើ ។ ដូចនេះ

ប្រជាជាតិយើងក៏បានបោះជំហានទៅមុខ មួយជំហានទៀតយ៉ាងសំខាន់ ពោលគឺបានចូលទៅកាន់ផ្លូវឯករាជ្យវប្បធម៌ ។ តាមពិត នរណាក៏ដឹងដែរថា វិស័យទាំងបីដ៏សំខាន់ គឺនយោបាយ សេដ្ឋកិច្ច និងវប្បធម៌នេះមានឥទ្ធិពលគាំទ្រគ្នាទៅវិញទៅមកយ៉ាងសកម្ម ។ ប្រទេសទើបនឹងបានឯករាជ្យនយោបាយក្នុងពិភពលោកទី៣បានយល់ការនេះ ហើយសព្វថ្ងៃ កំពុងតែខំប្រឹងកាត់ផ្តាច់នូវការជ្រៀតជ្រែករបស់អាណានិគមនិយមថ្មី ជាពិសេសតាមផ្លូវវប្បធម៌នេះ ។

សេចក្តីសំរេចដ៏ប្រសើររបស់សមាជជាតិនេះបានធ្វើឲ្យពលរដ្ឋយើងទូទៅ ជាពិសេសកម្មករ កសិករ មានសេចក្តីរីករាយជាពន់ពេក ។

គឺក្នុងបំណងនឹងផ្តល់វិភាគទានបំភ្លឺមិត្តសមាជិកយើងឲ្យកាន់តែបានជ្រួតជ្រាប ហើយជឿជាក់លើសមត្ថភាពនៃភាសាជាតិយើង ឲ្យឃើញការលំបាកខ្លះ ព្រមទាំងវិធីដោះស្រាយ

ជាបច្ចេកទេសខ្លះ ក្នុងការយកភាសាជាតិមកប្រើជាផ្លូវការនេះ ហើយ បានជាគណៈកម្មាធិការអចិន្ត្រៃយ៍នៃសមាគមចំរុះ បានប្រមូលឯកសារទាំងបីនេះមកបង្គ្រប់ឡើង :

១. សេចក្ដីថ្លែងការណ៍រួម នៃមហាសន្និបាតវិសាមញ្ញ នៃសមាគមទាំង ១០ ថ្ងៃ ៥ កក្កដា ១៩៦៧

២. សេចក្ដីពន្យល់របស់គណៈកម្មាធិការជាតិ ខាងខេមរយានកម្ម

៣. កំណត់ហេតុរបស់គណៈមេប្រយោគ ក្នុងពិធីថ្វាយសញ្ញាបត្រ "បណ្ឌិតខាងអក្សរសាស្ត្រ" ចំពោះសម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ ។

យើងសង្ឃឹមថា កំរងឯកសារនេះនឹងជួយមិត្តយើងឲយកាន់តែភ្លឺឡើងទៀត ចំពោះបញ្ហាប្រើភាសាខ្មែរជាយានទេះជាមិនខាន ។

គណៈកម្មាធិការអចិន្ត្រៃយ៍ នៃសមាគមចំរុះ

«ការប្រើភាសាខ្មែរជាយានក្នុងការសិក្សា ជាការចាំបាច់»

## សេចក្ដីថ្លែងការណ៍រួម
### នៃសមាគមទាំងដប់

ថ្ងៃ ៥ កក្កដា ១៩៦៧

ប្រតិភូនៃគណៈកម្មាធិការនាយកសមាគមទាំងដប់ គឺ សមាគម សាស្ត្រាចារ្យខ្មែរ,សមាគម បុគ្គលិកសិក្សាខ្មែរ សមាគម សាមគ្គីមិត្តសិស្សចាស់នឹងមិត្តសិស្សនៃអនុវិទ្យាល័យ នឹងវិទ្យាល័យព្រះស៊ីសុវត្ថិ, សមាគម សិល្បករនឹងវិចិត្រករខ្មែរ, សមាគម សង្គ្រោះបុគ្គលិកសាធារណការ, សមាគម ផ្លូវថ្កើង, សមាគម កម្ពុជបុត្រ, សមាគម បំរើនវិជ្ជា, សមាគម

សាធារណការ, នឹងសមាគម ទូទៅនៃនិស្សិតខ្មែរនៅប្រទេសកម្ពុជា បានមករួមប្រជុំជាមហាសន្និបាត កាលពីថ្ងៃ៥ កក្កដា ១៩៦៧ នៅទីស្នាក់ការសមាគមទូទៅនៃនិស្សិតខ្មែរ ហើយបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់ អំពីបញ្ហាពីរដ៏សំខាន់ ដែលជាឧត្តមគតិរួមរបស់សមាគមយើងទាំងអស់ផង ហើយក៏ជាសាខាមួយដ៏សំខាន់នៃវប្បធម៌ជាតិយើងផង គឺបញ្ហាប្រើភាសាជាតិជាផ្លូវការ នឹងបញ្ហាប្រើភាសាខ្មែរជាយានក្នុងការសិក្សា ។

បន្ទាប់ពីបានជជែកវែកញែករកហេតុផលសព្វគ្រប់មក មហាសន្និបាតក៏បានសំរេចអនុម័តជាឯកច្ឆន្ទ នូវសេចក្តីថ្លែងការណ៍រួមមួយចំពោះបញ្ហាខាងលើ ដូចតទៅនេះ

## ទី ១. បញ្ហាប្រើភាសាជាតិជាផ្លូវការ

### ក. អំពីការចាំបាច់

ប្រទេសយើងបានឯករាជ្យនយោបាយនឹងសេដ្ឋកិច្ច ១៤ ឆ្នាំមកហើយ ។ យើងខ្ញុំយល់ឃើញថា ឯករាជ្យខាងវប្បធម៌ គឺជាគ្រឹះមួយយ៉ាងមាំ សំរាប់ពង្រឹងជំហរឯករាជ្យនយោបាយ

នឹងសេដ្ឋកិច្ច ។

ការប្រើភាសាខ្មែរជាផ្លូវការនេះ នឹងនាំមកនូវសារៈប្រយោជន៍ច្រើនបែបច្រើនយ៉ាងណាស់ គឺនាំឲ្យប្រជាពលរដ្ឋយើងទូទៅ ជាពិសេស កម្មករ កសិករ ដែលតំណាងភាគច្រើនដ៏លើសលុបនៃប្រជាជាតិយើង យល់កិច្ចការរដ្ឋបានដោយងាយ ៗ ប្រជាពលរដ្ឋយើងនឹងពេញចិត្តថា ខ្លួនបានស្មើមុខនឹងអ្នកចេះដឹងហើយនឹងអ្នករាជការដែរ ។ ម្យ៉ាងទៀត ការប្រើអក្សរនឹងភាសាជាតិដូចគ្នា នឹងនាំឲ្យសាមគ្គីភាពរវាងពលរដ្ឋខ្មែរគ្រប់ជាន់ថ្នាក់មានកាន់តែខ្ពង់ខ្ពស់ឡើងទៀត ព្រោះប្រជាពលរដ្ឋយល់ថា ខ្លួនលែងចាញ់ប្រៀប លែងទន់ទាបជាងអ្នកចេះដឹង នឹងអ្នករាជការទៀតហើយ ។ ហេតុនេះ ក្នុងកាលៈទេសៈពិសេសដែលប្រជាជាតិយើងកំពុងតែត្រូវចក្រពត្តិអាមេរិកាំងនឹងបរិវារទាំងជិតទាំងឆ្ងាយ គំរាមកំហែងយ៉ាងមមាញឹក ហើយដែលរាជរដ្ឋាភិបាលពិសេសរបស់សម្ដេចឪ អំពាវនាវឲ្យលើកកំពស់សាមគ្គីភាពនឹងឯកភាពជាតិនេះ ការ

លើកយកភាសាជាតិមកប្រើជាផ្លូវការ ពិតជាឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ នឹងសេចក្ដីត្រូវការរបស់ស្ថានការណ៍ពន់ពេកណាស់ ។

ការប្រើភាសាជាតិនេះ គឺពិតជាការបញ្ចប់ព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យរបស់សម្ដេចឪ ពោលគឺឯករាជ្យខាងវប្ប-ធម៌ ស្របទៅតាមបាវចនាជាតិរបស់យើងថា " ខ្មែរជួយខ្លួនដោយខ្លួនឯង" ខ្មែរប្រើភាសាខ្មែរ ។ ម៉្យាងទៀត ការប្រើភាសាខ្មែរជាផ្លូវការនេះ នឹងធ្វើឲ្យកិត្តិសព្ទរបស់ប្រទេសយើងលើផ្ទៃអន្តរជាតិ ដែលខូចខាតស្រាប់មកហើយ កាន់តែលេចព្រន្លឺឡើងទៀត ហើយបង្ហាញឲ្យជនបរទេសយល់ច្បាស់ថា **ភាសាជាតិរបស់ខ្មែរមិនមែនជាភាសាបារាំងទេ** កុំឲ្យមានការកាន់ច្រឡំដូចជនជាតិអូស្ត្រាលីខ្លះដែលបានពោលថា នៅក្នុងប្រទេសយើង ភាសាបារាំងជាភាសារបស់ជាតិខ្មែរ (!)

ដូចនេះ ការយកភាសាជាតិមកប្រើជាផ្លូវការ គឺជាការចាំបាច់បំផុតរបស់ប្រទេសយើង ក្នុងកាលៈទេសៈសព្វថ្ងៃនេះ ។

ច្បាប់រដ្ឋធម្មនុញ្ញយើងក៏បានបញ្ញត្តទុកនូវការចាំបាច់នេះ តាំងតែពីឆ្នាំ ១៩៤៧ មកម៉្លេះ ។ ចំណែកឯពជរដ្ឋាភិបាលក៏បានយកបញ្ហានេះមកបកស្រាយ ដូចដែលសាពបរក្តី សមាជជាតិក្តី បានសំរេចនឹងដាស់តឿនក្រើនរំលឹកជាហូរហែមកស្រាប់ ។

## ១. អំពីមធ្យោបាយ

មហាសន្និបាតយល់ជាឯកច្ឆន្ទថា ភាសាខ្មែរយើងថ្វីត្បិតតែរអាក់រអួល ខាតពេលលូតលាស់អស់ជិត ១០០ ឆ្នាំ ព្រោះអាណានិគមនិយមបារាំងក្តី ក៏បានទទួលនូវការកែចំរើនយ៉ាងខ្លាំងក្នុងសម័យសម្តេចឪនេះ ហើយមានសមត្ថភាពអាចនឹងចូលមកជំនួសភាសាបារាំងបានយ៉ាងពិតប្រាកដ ។ ថ្វីត្បិតតែនៅខ្វះពាក្យបច្ចេកទេសខ្វះនៅឡើយ យើងក៏អាចនឹងប្រើភាសាជាតិយើងបាន ។ **ឱ្យតែយើងមានទិសនយោបាយច្បាស់លាស់អំពីការប្រើភាសាជាតិនេះ** ហើយចាប់អនុវត្តទៅ នោះការខ្វះខាតក្តី ការលំបាកក្តីក៏នឹងបានត្រូវដោះស្រាយជាបណ្តើរៗ ទៅហើយ ។

ក្នុងន័យនេះ ជាតិណាក៏នៅតែត្រូវការបង្កើតពាក្យពេចន៍ថ្មីថែមទៀតដែរ ។ បើចាំមានពាក្យគ្រប់គ្រាន់សិន ទើបចាប់ផ្ដើមប្រើភាសាជាតិជាផ្លូវការ ការរង់ចាំនេះមុខតែគ្មានទីបញ្ចប់ឡើយ ។

យើងខ្ញុំជឿជាក់ថា ភាសាខ្មែរមានសមត្ថភាពនឹងយកមកប្រើជាផ្លូវការបានជាប្រាកដ ; យើងខ្ញុំនឹងអនុវត្តការនេះខ្លួនឯង ក្នុងផ្ទៃសមាគមយើងរៀងៗខ្លួន ហើយទិទៀនមិត្តភក្តិដែលនិយមភាសាបរទេស ឬនិយមតាមភាសាខ្មែរនឹងបរទេសចំរុះគ្នា ; យើងខ្ញុំនឹងផ្សាយសេចក្ដីសំរេចចិត្តនេះទៅសមាគមនឹងអង្គការដទៃទៀត ហើយគាំទ្រយ៉ាងពេញទំហឹងគ្រប់ក្រសួងជាតិដែលទទួលភារៈកិច្ចដោះស្រាយបញ្ហានេះ ។

ដើម្បីនឹងអនុវត្តនូវឧត្តមគតិនេះ អង្គប្រជុំបានបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍មួយនៃមហាសន្និបាតចំរុះ ។

## ទី២. បញ្ហាប្រើភាសាខ្មែរជាយានក្នុងការសិក្សា

### ក. អំពីការចាំបាច់

ចំពោះខេរនីយកម្មការសិក្សា មហាសន្និបាតយល់ថាជាការចាំបាច់ណាស់ ពីព្រោះការប្រើភាសាខ្មែរជាយាននឹងផ្តល់អត្ថប្រយោជន៍ដ៏លើសលុបក្នុងវិស័យផ្សេងៗ ដូចតទៅ :

១. ចំពោះសិស្ស

ការពិសោធន៍រួចមកហើយបានបង្ហាញថា សិស្សខ្មែរយើងពិបាកនឹងយល់វិជ្ជា ដែលបង្រៀនជាភាសាបារាំងណាស់ ព្រោះគ្រាន់តែវិជ្ជាខ្លួនឯងនោះក៏ពិបាកស្រាប់ទៅហើយ ហើយថែមលើការលំបាកខាងភាសាទៅទៀត សិស្សខ្មែរត្រូវខំទ្វេឡើងជាពីរ ! ហើយទោះបីខំប្រឹងដូចនេះក្តី សិស្សយើងក៏នៅតែពិបាកនឹងចាប់វិជ្ជាដដែល ព្រោះនៅទើរត្រឹមតែរបងភាសាប៉ុណ្ណោះ ។ ដើម្បីបានពិន្ទុល្អនឹងប្រឡងជាប់ សិស្សយើងតែងតែនាំគ្នាទន្ទេញ „ចាំមាត់ដូចសេក" ហើយខំប្រវេប្រក

រកលុយកាក់រៀនឈ្នួលពេលវិស្សមកាល ឬរៀនឈ្នួលបន្ថែមពេលយប់ ៗ ចំពោះមាតាបិតា នេះជាបន្ទុកមួយដ៏ធ្ងន់ថែមទៀត ឯចំពោះសិស្សវិញ អ្នកបានរៀនមានរហូតដល់ធ្លាក់ខ្លួនឈឺ! ឯអ្នកមិនបានរៀន ដល់ចូលទៅវិញរៀនមិនទាន់គេ មានការអៀនខ្មាស ខ្លះរហូតដល់ទៅបោះបង់ការសិក្សាចោលផង ៗ

ប្រសិនបើរៀនវិជ្ជាជាភាសាខ្មែរវិញ បញ្ហាទាំងប៉ុន្មានខាងលើមិនកើតទេ ៗ សិស្សយើងអាចនឹងយល់បានងាយច្រើនជាង ហើយចាំបានងាយច្រើនជាងរៀនជាភាសាបារាំងៗ ដូចនេះ ក្នុងការសិក្សា គេមានឱកាសនឹងពិចារណារកហេតុផលបានច្រើន មានឱកាសនឹងធ្វើពលកម្មផ្សេងៗ នឹងលេងកីឡា ហើយនឹងរៀនភាសាបរទេសឯទៀតៗបានម៉ត់ចត់ ៗ សិស្សយើងនឹងបានធូរខួរក្បាល បែកប្រាជ្ញា ដុះគំនិតស្នេហាជាតិ ហើយមានអាកប្បកិរិយា នឹងដំហរស្នេហាជាតិដ៏រឹងប៉ឹង ៗ

ហេតុនេះមហាសន្និបាតមានជំនឿជឿជាក់ថា ការបង្រៀនជាភាសាខ្មែរពិតជានឹងបណ្ដុះបណ្ដាលនូវជំនាន់យុវជនមួយដ៏មានសមត្ថភាព ប្រកបទៅដោយសម្បជញ្ញៈជាតិដ៏ជាក់លាក់ដែលរៀបចំអនាគតពលរដ្ឋមានស្មារតីទទួលខុសត្រូវ អនាគតករ ហើយនឹងអនាគតអ្នកប្រាជ្ញជាទីសង្ឃឹមរបស់ប្រទេសជាតិ។

២. ចំពោះគ្រូ

ការបង្រៀនជាភាសាបាំង ពុំមែនពិបាកចំពោះតែសិស្សប៉ុណ្ណោះទេ គ្រូក៏ពិបាកខ្លាំងណាស់ដែរ ។

យ៉ាងណាមិញ គ្រូខ្មែរយើងភាគច្រើនដែលចេះបាំងតិចជាងចេះវិជ្ជា ត្រូវប្រើពេលឥតប្រយោជន៍ច្រើនណាស់ក្នុងការរៀបចំកិច្ចការរបស់ខ្លួន ដើម្បីនឹងទៅនិយាយជាបាំងឲ្យសិស្សខ្មែរស្ដាប់ ។ ក្នុងការពន្យល់ គ្រូក៏ពន្យល់មិនបានក្បោះក្បាយដូចចិត្តទៀត ពីព្រោះខ្លួនលោកក៏ពិបាកក្នុងរឿងភាសានេះដែរ ។ សិស្សស្ដាប់មិនបាន លោកគ្រូក៏

ត្រូវពន្យល់ជាខ្មែរសាឡើងវិញម្ដងទៀត; លោកគ្រូពិបាកចិត្ត ហើយហត់នឿយជាខ្លាំង ។ សិស្សក៏នឿយណាយក្នុងការសិក្សា ហើយបញ្ចេញអាកប្បកិរិយាធុញទ្រាន់ ផ្គាំផ្គួន ជាហេតុនាំឲ្យមានទំនាស់រវាងសិស្សនឹងលោកគ្រូ ដែលសុទ្ធតែមានគោលបំណងល្អចង់បេះនឹងចង់ឲ្យបេះដូចៗគ្នា ។ ក្នុងផ្នែកគ្រូវិញ ក៏សឹងតែមានការរើសអើងគ្នា រវាងអ្នកពូកែបារាំងនឹងអ្នកមិនសូវពូកែបារាំងថែមទៀត ។

ប្រសិនបើបង្រៀនវិជ្ជាជាខ្មែរវិញ គ្រូមានមធ្យោបាយច្រើននឹងពន្យល់ឲ្យបានក្បោះក្បាយ ហើយសិស្សក៏ត្រងត្រាប់បានផលយ៉ាងជាក់ស្ដែង ។ ឯបរិយាកាសសាមគ្គីភាពក៏មានជានិច្ច រវាងគ្រូនឹងសិស្សក្ដី រវាងគ្រូនឹងគ្រូក្ដី ។

៣. បំពោះជាតិ

មហាសន្និបាតនៃសមាគមចំរុះយល់ឃើញថា ការបង្រៀនជាភាសាបារាំងតំរូវឲ្យរដ្ឋយើងចំណាយរូបិយបណ្ណ

ក្នុងមួយឆ្នាំៗ អស់ច្រើនលានណាស់ ចាយទៅខាងទិញ
សៀវភៅផង ទៅខាងជួលនឹងផ្គត់ផ្គង់សាស្ត្រាចារ្យបារាំង
ផង ៗ រីឯលទ្ធផលវិញ ឃើញថាបានតិចតួចស្តួចស្តើង
ខ្លាំងណាស់ មិនធួនល្មមនឹងចំណាយរបស់យើងទេ សមដូច
សហជីវិននាយកមធ្យមសិក្សាបានសន្និដ្ឋានក្នុងសេចក្តីរាយការ
របស់លោកស្រាប់ ៗ មិនតែប៉ុណ្ណោះ ការបង្រៀនជា
ភាសាបារាំងបង្កើតនូវផលវិបាកផ្សេងៗច្រើន : ម៉្យាងគឺ
ផ្ទុយពីនយោបាយត្បិតត្បៀត សន្សំប្រិយបណ្ណរបស់សម្តេច
សហជីជីវិន; –ម៉្យាង នាំឲ្យយុវជនយើងមិនសូវជឿជាក់លើ
តំលៃពិតប្រាកដនៃភាសានឹងវប្បធម៌ជាតិ ហើយបែរជាស្ញើច
សរសើរ “ធ្លាញ់” តែនឹងវប្បធម៌បរទេសទៅវិញ; – ហើយ
ម៉្យាងទៀត សាស្ត្រាចារ្យបារាំងខ្លះឆ្លៀតឱកាសនេះដើម្បីនឹង
**អប់រំអូសទាញសិស្សយើង** សំរបទៅតាមផលប្រយោជន៍
នយោបាយរបស់ខ្លួនទៅវិញ ៗ

ប្រសិនបើបង្រៀនជាខ្មែរវិញ នោះប្រជាជាតិយើងនឹង

ចំណេញរូបិយបណ្ណបានរាល់លាន នាំឲ្យរាជរដ្ឋាភិបាលអាចដោះស្រាយបញ្ហាជាតិផ្សេងៗទៀតបាន មានបញ្ហាបង្កើនចំនួនគ្រូជាដើម ៗ លើសពីនេះទៅទៀត ការបង្រៀនជាខ្មែរប្រឡងជាខ្មែរ នាំឲ្យបេក្ខជនដែលមានសត្ថភាពពិតប្រាកដ មានបរិយាស្អាតស្អំ ប៉ុន្តែគ្រាន់តែខ្សោយខាងភាសាបារាំងប៉ុណ្ណោះ អាចនឹងប្រឡងជាប់បានផង ៗ

ពិសេសទៅទៀត ការសិក្សាវិជ្ជាជាភាសាខ្មែរនឹងសាបព្រោះនូវបំណេះវិជ្ជាដ៏ជាក់លាក់ជ្រៅជ្រះ នូវ ពាក្យពេចន៍នឹងភាសាដ៏សំបូរព្រមទាំងគំនិតស្នេហាជាតិដ៏មោះមុត ជាវិធានការមួយដ៏ទូលំទូលាយ យូរអង្វែងសំរាប់ដោះស្រាយដល់ឫសគល់ នូវបញ្ហាទាំងប៉ុន្មានដែលចោទមកខាងលើ ៗ

## ១. អំពីមធ្យោបាយ

ចំពោះវិធីដោះស្រាយខេមរនីយកម្ម ដែលប្រជាជាតិនឹងយុវជនយើងកំពុងតែត្រូវការជាប្រញាប់នេះ មហាសន្និបាត

យល់ឃើញថា យើងត្រូវជ្រើសរើសវិធីណាដែលអាចឲ្យចាប់ផ្ដើមអនុវត្តបានក្លាមផង ដែលធាកក៏ប់រងអំពីគុណភាពផង ហើយដែលតំរូវឲ្យចាយវាយតែបន្តិចបន្តួចផង ។

ក្នុងគំនិតនេះមហាសន្និបាតសូមស្នើគោលការណ៍ដូចតទៅ:

## អំពីគោលការណ៍

បញ្ហាខេមរនីយកម្មនេះ ប្រសិនបើរង់ចាំការតែងសៀវភៅឲ្យបានចប់សព្វគ្រប់សិនទើបចាប់អនុវត្ត នោះផលប្រយោជន៍ជាតិនឹងយុវជនយើងនឹងត្រូវខាតបង់អស់ច្រើនឆ្នាំទៀត ហើយពុំអាចនឹងចេញរួចឡើយ ។ ហេតុនេះ យើងខ្ញុំសូមស្នើធ្វើសៀវភៅបណ្ដើរ បង្រៀនជាខ្មែរបណ្ដើរ ដោយពឹងផ្អែកលើសមត្ថភាព លើសហប្រតិបត្តិការ និងគំនិតស្នេហាជាតិរបស់សាស្ត្រាចារ្យយើង ។

## អំពីវិធានការ

ចាប់តាំងពីឥឡូវនេះទៅ ក្រសួងមានសមត្ថកិច្ចប្រកាសធ្វើខេមរនីយកម្ម ដោយណែនាំសាស្ត្រាចារ្យឲ្យរៀបចំធ្វើមេ

រៀនជាភាសាខ្មែរបណ្ដើរ បង្រៀនជាភាសាខ្មែរបណ្ដើរ ។

គណៈកម្មការមានសមត្ថកិច្ចនឹងផ្ដល់ពាក្យគន្លឹះ **les mots clés** ក្នុងមុខវិជ្ជានីមួយៗ នៃថ្នាក់នីមួយៗ ដើម្បីឲ្យមានឯកភាពក្នុងការប្រើប្រាស់ ។

ក្នុងវិស្សមកាលក្រោយ គណៈកម្មាធិការបច្ចេកទេសមានសមត្ថកិច្ច នឹងប្រមូលមេរៀនល្អៗពីសាលាផ្សេងៗក្នុងព្រះរាជអាណាចក្រ យកមករៀបចំសំរួលឲ្យបានជាមេរៀនល្អ ហើយវៃរ៉ូណេអូសំរាប់បង្រៀនជាបណ្ដោះអាសន្នសិន ។

ក្នុងវិស្សមកាលក្រោយទៀត គណៈកម្មាធិការបច្ចេកទេសប្រមូលមេរៀនរ៉ូណេអូនេះ ព្រមទាំងសេចក្ដីទិទៀន នឹងសេចក្ដីស្នើអំពីសាស្ត្រាចារ្យក្នុងព្រះរាជអាណាចក្រ ។

គណៈកម្មាធិការលំអមេរៀន ទៅតាមយោបល់ស្នើទាំងនេះ ។ មេរៀននៅរក្សាសភាពជាវៃរ៉ូណេអូដដែល គ្រាន់តែលំអខាងខ្លឹមសារប៉ុណ្ណោះ ហើយនឹងប្រែក្លាយទៅជាសៀវភៅ លុះត្រាតែគណៈកម្មាធិការយល់ឃើញថា ទាំងខ្លឹមសារ

ទាំងទំរង់ ទាំងវិធីសាស្ត្រ មានកំរិតខ្ពស់ល្មមនឹងបោះជាសៀវភៅបានហើយ ។

អាស្រ័យហេតុនេះ មហាសន្និបាតនៃសមាគមបំរុះយល់ឃើញថា បញ្ហាខេមរនីយកម្មដែលមានជនខ្លះយកទៅបកស្រាយដោយបំណាងអាក្រក់ ឬយកទៅពង្រីកបន្ទាបគេឯងនោះ អាចនឹងដោះស្រាយបាន ទៅតាមមធ្យោបាយដែលយើងមាន ទៅតាមពេលវេលាដែលយើងមាន និងក្នុងក្របខណ្ឌនៃនយោបាយត្រឹមត្រូវរបស់យើង ។ បំពោះលទ្ធផលវិញ យើងខ្ញុំជឿជាក់ថា នឹងបានប្រសើរជាងបង្រៀនជាភាសាបារាំងទៅទៀត ពីព្រោះសិស្សខ្មែរយល់ភាសាខ្មែរជាងភាសាបារាំង ។

ហើយយើងខ្ញុំជឿជាក់ថា **ខេមរនីយកម្មអាចនឹងចាប់ផ្តើមពីថ្នាក់ទី៦ នឹងថ្នាក់ទី៥ ចាប់ពីឆ្នាំសិក្សា ១៩៦៧-៦៨ នេះទៅ ។**

## គ. អំពីជីវភាសា

ក្នុងការធ្វើសំណូមពរ ឲ្យក្រសួងមានសមត្ថកិច្ចធ្វើខេមរនីយកម្មការសិក្សានេះ មហាសន្និបាតយល់យ៉ាងច្បាស់អំពីសារៈសំខាន់នៃភាសាបរទេស ។ ហេតុនេះ យើងយល់ថាភាសាបរទេសត្រូវតែរៀន ប៉ុន្តែរៀន ត្រឹមតែជាជីវភាសាប៉ុណ្ណោះ **en tant que langue vivante** ប៉ុន្តែពុំមែនរៀនជាយានភាសាទេ **et non en tant que langue véhicule** ។ ម្យ៉ាងទៀត ហើយដើម្បីឲ្យយុវជនយើងមាន“ ដំបូលទូលាយឆ្ពោះទៅរកសាកលលោក” យុវជនយើងត្រូវតែរៀនភាសាបរទេសឱ្យបានច្រើន ជាពិសេសភាសាជនជាតិណា ដែលខ្មែរមានការទាក់ទងហើយត្រូវការប្រើប្រាស់ញឹកញាប់ មានចិនអង់គ្លេស វៀតណាម ជប៉ុន បារាំង ... ជាដើម ។

ឯភាសាបរទេសនេះសោតទៀត ការពិសោធន៍បានបង្ហាញថា ការសិក្សានឹងផ្ដល់ផលល្អ លុះណាតែសិក្សានៅក្នុងវិជ្ជាស្ថានពិសេសសំរាប់ភាសាបរទេស ហើយលុះណាតែ

អ្នកសិក្សានេះចេះភាសាជាតិរបស់ខ្លួនឱ្យបានច្បាស់លាស់ជាមុនសិន ។

នេះជាយោបល់របស់យើងខ្ញុំ ចំពោះបញ្ហាប្រើភាសាខ្មែរជាផ្លូវការ ទឹងបញ្ហាប្រើភាសាខ្មែរជាយានក្នុងការសិក្សា ។

មហាសន្និបាតនៃសមាគមចំរុះ សូមអំពាវនាវបងប្អូនរួមជាតិ ចាប់អារម្មណ៍ដល់បញ្ហាឯករាជ្យវប្បធម៌របស់យើងឲ្យបានជាអតិបរមា ជាពិសេស សូមក្រសួងមានសមត្ថកិច្ចលៃលកអនុវត្តតាមសំណូមពររបស់យើងខ្ញុំខាងលើនេះ ដើម្បីផលប្រយោជន៍របស់យុវជន ទឹងផលប្រយោជន៍របស់ជាតិយើង ។

“សិស្សរៀនវិជ្ជាជាភាសាខ្មែរ ធូរខួរក្បាល ងាយយល់ ងាយចាំ ងាយចេះ ។ ”

សេចក្ដីថ្លែងការណ៍រួម—5 - 7 - 67

សិស្សរៀនវិជ្ជាជាភាសាខ្មែរ មានពេលរៀនភាសាបរទេស មានពេលបង្កើនការចេះដឹងទូទៅ មានពេលលេងកីឡា និងរៀនការងារ ។

# អំពីខេមរនីយកម្ម :

# អំពីខេមរនីយកម្មក្នុងការសិក្សា

ដោយ

## គណៈកម្មការរៀបចំ
## និងអនុវត្តខេមរនីយកម្ម

មិថុនា ១៩៦៧

## កថាមុខ

*រដ្ឋមន្ត្រីក្រសួងអប់រំជាតិបានទទួលសំណូមពរជាច្រើន ពីមជ្ឈដ្ឋាននានា ដូចជាមជ្ឈដ្ឋានព្រះសង្ឃ នាយកមធ្យមសិក្សា សមាគមសាស្ត្រាចារ្យ សមាគមកម្ពុជបុត្រ ជាដើម សុំឲ្យប្រើភាសាខ្មែរជាភាសាយានក្នុងការសិក្សា ។*

ដោយយល់ឃើញថា សំណូមពរទាំងនោះមានសភាព សមហេតុសមផលណាស់ គួរឲ្យយកមកពិនិត្យហើយឆ្លើយតបវិញ រដ្ឋមន្ត្រីក្រសួងអប់រំជាតិ បានដាក់សំណូមពរនេះឲ្យឧត្តមក្រុមប្រឹក្សាសាកលវិទ្យាល័យពិភាក្សានៅថ្ងៃទី ១០ មិថុនា គ.ស. ១៩៦៧ ហើយបានសំរេចបង្កើតគណៈកម្មការមួយ ដើម្បីរៀបចំធ្វើខេមរនីយកម្ម ក្នុងការសិក្សា ។

ក្រសួងអប់រំជាតិយល់ឃើញថា ខេមរនីយកម្ម ក្នុងការសិក្សានេះជាការមួយពិបាកពន់ប្រមាណ ។ បុគ្គលិកអ្នកទទួលភារៈនេះ ត្រូវមានចិត្តជាតិនិយមយ៉ាងជ្រាលជ្រៅ ហ៊ានបូជាពេលវេលាទំនេររបស់ខ្លួន មានសេចក្ដីក្លាហានទឹងសំរេច មានសេចក្ដីព្យាយាមយ៉ាងស្វិតស្វាញ ។

ការធ្វើខេមរនីយកម្មក្នុងការសិក្សាពិបាកមែនហើយ ប៉ុន្តែយើងត្រូវតែធ្វើ ពីព្រោះ នេះជាផលប្រយោជន៍របស់យុវជនខ្មែរទូទៅ របស់វប្បធម៌ខ្មែរ និងជាតិខ្មែរទាំងមូល ។

ក្រសួងអប់រំជាតិមានសេចក្ដីសោមនស្សយ៉ាងពន់ប្រ

មាណដោយយល់ឃើញបុគ្គលិកសិក្សាខ្មែរយើងបានចាប់អារម្មណ៍ទៅលើបញ្ហាភាសាយានក្នុងការសិក្សា ហើយរួបរួមគ្នាជាមួយក្រសួងអប់រំជាតិដើម្បីដោះស្រាយបញ្ហានោះ ដោយសេចក្ដីស្នេហាជាតិមាតុភូមិ ។

វណ្ណ ម៉ូលីវណ្ណ

●

## សេចក្ដីផ្ដើម

ការប្រជុំរបស់ឧត្ដមក្រុមប្រឹក្សាសាកលវិទ្យាល័យ បានសំរេចបង្កើតគណៈកម្មការរៀបចំធ្វើខេមរនីយកម្មមួយ ក្នុងការសិក្សា កាលពីថ្ងៃទី ១០ មិថុនា គ.ស ១៩៦៧ ។

គណៈកម្មការនេះបានធ្វើការប្រជុំជាច្រើនលើក ដដែក

ពិភាក្សា ហើយបានសំរេចធ្វើបេកម្មភាពពីរធំៗ គឺ :

ទី១ រៀបចំធ្វើទំរង់អង្គការមួយ ដែលមានទ្រង់ទ្រាយដូចតទៅនេះ ៖ មានគណៈកម្មការរៀបចំនឹងអនុវត្តខេមរនីយកម្មក្នុងការសិក្សាមួយដែលទាក់ទងទៅនឹង

– បណ្ឌិតសភា (បំរុងនឹងកើត) – គណៈកម្មការវប្បធម៌

– ទីចាត់ការឧត្តមសិក្សា – ទីចាត់ការមធ្យមសិក្សា

– ទីចាត់ការបឋមសិក្សា – ទីចាត់ការគរុកោសល្យ

– ឧត្តមក្រុមប្រឹក្សាសាកលវិទ្យាល័យ – វិទ្យាស្ថានជីវភាសា (មើលតារាង)

គណៈកម្មការរៀបចំនឹងអនុវត្តខេមរនីយកម្ម ក្នុងការសិក្សានេះ នឹងស្នើសុំឲ្យក្រសួងអប់រំជាតិបង្កើតជារបស់រាជការនូវគណៈកម្មការបច្ចេកទេសខេមរនីយកម្មមួយ ដែលមាននៅពីក្រោមខ្លួននូវគណៈកម្មការរងគ្រប់មុខវិជ្ជា ពោលគឺ:

– គណៈកម្មការរងលោកនីតិវិជ្ជា – គ.រងខាងប្រវត្តិវិទ្យា

– – នីតិសីលៈវិជ្ជា – – និងភូមិវិទ្យា

– – ទស្សនវិជ្ជា – – ធម្មជាតិវិទ្យា

– – រូបវិទ្យា និងគីមីវិទ្យា – – គណិតវិទ្យា

— គ.រង បច្ចេកទេសវិទ្យា — គ.រង ក្សេត្រវិទ្យា

— — មុខវិជ្ជាផ្សេងៗ — — បកប្រែសៀវភៅទូទៅ

ទី២. *រៀបចំធ្វើសៀវភៅមួយ ស្ដីអំពីការប្រើភាសាខ្មែរជាភាសាយានក្នុងការសិក្សា គឺសៀវភៅនេះឯង ។ សៀវភៅនេះនឹងអធិប្បាយអំពីហេតុ ដែលនាំឲ្យយកភាសាខ្មែរមកធ្វើជាភាសាយាន អំពីផលប្រយោជន៍ដែលកើតឡើងពីហេតុនេះ អំពីលទ្ធភាពដែលនាំឲ្យអនុវត្តការផ្លាស់ប្ដូរភាសាយាននេះបានក្នុងការសិក្សា នឹងអំពីវិធីផ្សេង ៗ ដែលនាំឲ្យយើងអនុវត្តការនោះបាន ។*

*យើងសង្ឃឹមថា ប្រជាជាតិខ្មែរទូទៅ បន្ទាប់ពីបានអានកូនសៀវភៅនេះមក នឹងបានស្គាល់ពិតប្រាកដ នូវបញ្ហាភាសាយានដែលទាក់ទងលើការសិក្សាក្នុងកម្ពុជរដ្ឋ នឹងវិធីដោះស្រាយបញ្ហានោះ ដើម្បីធ្វើឲ្យវប្បធម៌ជាតិយើងមានលក្ខណៈជាតិបរិបូរឡើង ។*

# សមាសភាពគណៈកម្មាធិការជាតិ

(តាមលិខិតបង្គាប់ការ លេខ ៥០៦ ក.ន.)

បានបង្កើតគណៈកម្មាធិការមួយ ហៅថា គណៈកម្មាធិការជាតិអប់រំនៃខេមរយានកម្មនៃការសិក្សា ដែលមានសមាសភាពដូចតទៅនេះ

សហជីវិន ហង្ស ធុន ហាក់ តំណាងរដ្ឋមន្ត្រីក្រសួងអប់រំជាតិ . . . ប្រធាន

— តៃ ម៉េង ហាប់ តំណាងតួទីកសាកលវិទ្យាល័យ អនុប្រធាន

— ព្រំម សំអារតំណាងសាកលវិទ្យាល័យភូមិន្ទបច្ចេកទេស —

— ស៊ុំ ឈុំ តំណាងសាកលវិទ្យាល័យប្រជារាស្ត្រ សមាជិក

— ដួង សារិន តំណាងសាកលវិទ្យាល័យភូមិន្ទ . . . —

— ព្រុំ នួនថុលតំណាងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ —

— លាង ហាប់ អាន តំណាងក្រសួងធម្មការ . . . —

សហ.កែវ ថែម   តំណាងមធ្យមសិក្សា ... សមាជិក

— ប៊ូរ ខាំ ម៉ៅ   តំណាងបឋមសិក្សា ... —

— ម៉ៃ លន់   តំណាងទីចាត់ការកិច្ចការគរុកោសល្យ —

— ង៉ូវ រ៉ា   តំណាងយុវជនរាជសង្គមនិយមខ្មែរ ...

— តំណាងសមាគមបុគ្គលិកសិក្សាចំនួនបីរូប ... —

— តំណាងសមាគមសាស្ត្រាចារ្យខ្មែរចំនួនពីររូប ... —

— តំណាងសមាគមទាំងដប់ចំនួនពីររូប .... —

— គង់ អ៊ិន នៅនាយកដ្ឋានមធ្យមសិក្សា .. អគ្គលេខាធិការ

សមាជិកនៃគណៈកម្មាធិការនេះ ទទួលរួមប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន ។

ភ្នំពេញ ថ្ងៃទី ៥ សីហា គ.ស. ១៩៦៧

រដ្ឋមន្ត្រីក្រសួងអប់រំជាតិ

ហត្ថលេខា: វ័ណ្ណ ម៉ូលីវ័ណ្ណ

## ទំរង់អង្គការ


រដ្ឋមន្ត្រី
ទីចាត់ការនានា
ឧត្តមក្រុមប្រឹក្សាសាកលវិទ្យា.
សាកលវិទ្យា.នានា
បណ្ឌិតសភា
គណៈកម្មាធិការរៀបចំ
នឹង អនុវត្ត ខេមរនីយកម្ម
វិទ្យាស្ថានភាសា
គណៈកម្មការ វប្បធម៌
សមាគមនានា
គណៈកម្មាធិការបច្ចេកទេស
លោកនីតិវិជ្ជា
នឹង សីលវិជ្ជា
មនុស្សវិជ្ជា
គណិតវិទ្យា
បច្ចេកវិទ្យា
វិជ្ជាផ្សេងៗ
ប្រវត្តិវិទ្យា-ភូមិវិទ្យា
រូបវិទ្យា-គីមីវិទ្យា
ធម្មជាតិវិទ្យា
ក្សេត្រវិទ្យា
ប្រែសៀវភៅ

# មូលហេតុដែលនាំឱ្យធ្វើខេមរនីយកម្ម ក្នុងការសិក្សា

## ១. ហេតុនយោបាយ

ក. ប្រទេសខ្មែរឯករាជមានភាសាជាតិរបស់ខ្លួនដែលមានក្បួនច្បាប់នឹងឯកភាព គួរតែប្រើភាសារបស់ខ្លួននេះ ។ វប្បធម៌ជាមែកធាងសំខាន់មួយនៃអរិយធម៌ ។ វប្បធម៌មានលក្ខណជាតិ អរិយធម៌ក៏មានលក្ខណៈជាតិដែរ ។

ការប្រើ ការពឹងលើភាសាជាតិមានលក្ខណៈស្របនឹងព្រះរាជនយោបាយសម្ដេចឪដែលថា : “ ប្រទេសកម្ពុជាពឹងលើខ្លួនឯង ” ។ ការលើកតំកើងភាសាជាតិ មានសភាពសមហេតុសមផល ត្រឹមត្រូវតាមព្រះរាជសាសន៍សម្ដេចឪក្នុងព្រះរាជសុន្ទរកថាថ្វាយសញ្ញាប័ត្របណ្ឌិតខាងអក្សរសាស្ត្រចំពោះព្រះសង្ឃរាជថ្នាក់ទីមួយ “ ជួន-ណាត ” ដែលថា: “ជាមួយនឹងឯករាជ្យជាតិ ភាសាជាតិត្រូវមាននាទីដ៏ធំហើយចំ

ពេញមុខការដ៏ខ្ពង់ខ្ពស់ ,, ។

ខ. រដ្ឋធម្មនុញ្ញយើងបានតំរូវឱ្យប្រើភាសាជាតិជាផ្លូវការគ្រប់វិស័យ ( មាត្រាទី ២ ) ។

## ២. ហេតុបច្ចេកទេស

ក. តាមភាសាបរទេសដែលជាភាសាយាន សិស្សខ្មែរ មានសេចក្ដីលំបាកក្រៃលែង ក្នុងការរៀនមុខវិជ្ជាផ្សេង ៗ ដោយគេពុំអាចរៀនភាសានោះចេះគ្រប់គ្រាន់ ។ ជាពិសេសគេសង្កេតឃើញថា សព្វថ្ងៃនេះ សិស្សរៀនមុខវិជ្ជាផ្សេង ៗ ជាបារាំងពុំបានចេះច្បាស់លាស់ឡើយ ពីព្រោះសិស្សត្រូវយល់ភាសាបារាំងផង ហើយត្រូវយល់ខ្លឹមសារវិជ្ជាទៀត ។

ខ. សាស្ត្រាចារ្យខ្មែរក៏មានការលំបាកនឹងបង្រៀនសិស្សខ្មែរតាមភាសាបារាំងដែរ ពីបាកទាំងពន្យល់ ពីបាកទាំងកែវិញ្ញាសាផ្សេងៗ ។

គ. ការរៀនតាមភាសាបារាំង តំរូវឱ្យមានសៀវភៅបារាំងដែលថ្លៃផង ហើយពីបាករកផង ។

# ផលប្រយោជន៍នៃខេមរនីយកម្មក្នុងការសិក្សា

## ១. ចំពោះនយោបាយជាតិ

ក. ខេមរនីយកម្មក្នុងការសិក្សានាមកនូវការស្របស្រួលទឹងមូលហេតុខាងដើមដែលថែងថា ប្រទេសខ្មែរឯករាជ គួរគប្បីប្រើភាសាជាតិរបស់ខ្លួនជាផ្លូវការទឹងក្នុងការសិក្សា ទឹងគួរគប្បីអនុវត្តរដ្ឋធម្មនុញ្ញ ដែលតម្រូវឲ្យប្រើភាសាជាតិនោះជាផ្លូវការ ។

ខ. ខេមរនីយកម្មក្នុងការសិក្សានាំមកនូវបច្ច័យសំខាន់បំផុតដើម្បីដោះស្រាយបញ្ហាសិក្សា បញ្ហាអប់រំ មុនពេលដែលបញ្ហានោះបានផ្ទុះឡើង ។

គ. ខេមរនីយកម្មក្នុងការសិក្សានាំឲ្យប្រទេសខ្មែរយើងរឹតតែមានកិត្យានុភាពកាន់តែខ្ពស់ឡើងទៀត ។

## ២. ចំពោះសេដ្ឋកិច្ចជាតិ

ក. ខេមរនីយកម្មក្នុងការសិក្សានាំឲ្យប្រទេសខ្មែរធ្វើសៀវភៅសិក្សាខ្លួនឯង ជាកិច្ចនាំឲ្យលែងមានការទិញសៀវ

ទៅពីបរទេសច្រើនពេក ។ ប្រទេសជាតិនឹងបានចំណេញរូបិយបណ្ណមួយភាគធំ ។

ខ. ពងការខ្មែរអាចបន្ថយការចំណាយរូបិយបណ្ណសំរាប់ជួលសាស្ត្រាចារ្យបរទេសបានជាច្រើន ។

គ. សេដ្ឋកិច្ចខ្មែរខាងការលក់ដូរសៀវភៅល្អ ៗ នឹងមានលទ្ធភាពចំរើនជាលំដាប់ ។

## ៣. ចំពោះវប្បធម៌ជាតិ

ខេមរនីយកម្មក្នុងការសិក្សា នឹងធ្វើឲ្យភាសាខ្មែររីកដុះដាលមានរស្មីភ្លឺចិញ្ចែងចិញ្ចាច ធ្វើឲ្យប្រទេសខ្មែរ មានសៀវភៅជាភាសាខ្មែរសំបូរឡើង ៗ វប្បធម៌ខ្មែរក៏កាន់តែលូតលាស់ខ្លាំងឡើងទៀត ។

## ៤. ចំពោះការអប់រំ

ក. ខេមរនីយកម្មនេះ នឹងជួយធ្វើឲ្យកម្មវិធីសិក្សា ក ខ គ បានត្រូវអនុវត្តដោយជោគជ័យ ។

ខ. ការអប់រំសិក្សាខាងផ្លូវកាយ ខាងផ្លូវចិត្ត ក៏នឹងធ្វើ

ឡើងបានដោយងាយនឹងបានលទ្ធផលល្អ ។

គ. ការបណ្ដុះចិត្តជាតិនិយមរបស់យុវជន ទាំងឡាយ កាន់តែជិតដល់ឡើងទៀត ។

ឃ. គួរបញ្ជាក់ថា ការយកភាសាខ្មែរជាភាសាយាន បានផលពិសេសមួយថែមទៀត គឺការសល់ពេលបំពប់យកទៅរៀនជីវភាសា ។ ដូចនេះ ការរៀនភាសាបរទេសរឹតតែបានប្រសើរជាងសព្វថ្ងៃ ។

## លទ្ធភាពធ្វើខេមរនីយកម្មក្នុងការសិក្សា

សំនួរដែលសួរឡើងថា តើគេអាចធ្វើខេមរនីយកម្មក្នុងការសិក្សាបានឬទេ នាំឲ្យយើងលើកយកឧបសគ្គគ្រប់បែបយ៉ាងដែលជំទាស់នឹងខេមរនីយកម្មនោះ មកបង្ហាញ ហើយផ្ដល់វិធីដោះស្រាយបន្ទាប់ៗគ្នា ។

**ឧបសគ្គទី១**: មតិខ្លះអះអាងថា មិនអាចធ្វើខេមរនីយកម្មក្នុងការសិក្សាបានទេ ពីព្រោះគ្មានសាស្ត្រាចារ្យ គ្មានសៀវភៅ

សិក្សាជាភាសាខ្មែរ ។

ការដោះស្រាយ: ប្រសិនបើគ្មានគ្រូ គ្មានសៀវភៅ យើងអាចបង្កើតបាន ។ ប្រទេសគេជិតខាងយើង គេអាចដោះស្រាយបញ្ហានេះបានរួចទៅហើយ ។ (គណៈកម្មការបច្ចេកទេសនឹងគណៈកម្មការវប្បធម៌ ជានាទីដោះស្រាយបញ្ហានេះ) ។ គួរបញ្ជាក់ថា ប្រទេសយើងសព្វថ្ងៃ មានសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ ចំនួន ១.៤៧៩ នាក់ហើយ សំរាប់មធ្យមសិក្សា ។ សៀវភៅជាខ្មែរក៏មានខ្លះដែរ បោះពុម្ពដោយពុម្ពគីមហាវិទ្យាល័យព្រះសីហនុរាជ ។ មហាវិទ្យាល័យនេះបានយកភាសាខ្មែរជាភាសាយានរួចទៅហើយ គេនឹងផ្តល់ការពិសោធន៍ដល់យើងពុំខាន ។

ឧបសគ្គទី២: មតិខ្លះថា ភាសាខ្មែរខ្វះពាក្យ ហើយគ្មានឯកភាព មិនអាចយកទៅធ្វើជាភាសាយានបាន ។

ការដោះស្រាយ: ការសិក្សាភាសាខ្មែរជ្រៅជ្រះតាមវិទ្យាវិធីបង្ហាញយ៉ាងច្បាស់ក្រឡែតថា ភាសាខ្មែរមិនខ្វះ

ពាក្យទេ ហើយមានឯកភាពគ្រប់គ្រាន់ល្មមប្រើជាភាសាយាន បាន (គណៈកម្មការបច្ចេកទេសនិងគណៈកម្មការវប្បធម៌ ជានាទីដោះស្រាយបញ្ហានេះ) ។

ឧបសគ្គទី៣: ការរៀនជាភាសាខ្មែរនាំឲ្យសិស្សខ្មែរទៅបន្តវិជ្ជានៅបរទេសពុំកើត ។

ការដោះស្រាយ: និស្សិតខ្មែរច្រើនគរគោក ខ្លះទៅរៀននៅសាធារណរដ្ឋប្រជាមានិតចិន នៅប្រទេសអាល្លឺម៉ង់ នៅសហភាពសូវៀត នៅ ចិកូស្លូវ៉ាគី នៅយូហ្គោស្លាវី ។ ល ។ ការជាក់ស្តែងបង្ហាញថា និស្សិតទាំងនោះអាចបន្តវិជ្ជាបានដោយជោគជ័យ មិនចាំបាច់តែទៅប្រទេសបារាំងនោះទៀយ ចូលរិតតែគេពុំដែលបានរៀនភាសាប្រទេសទាំងនោះ ។ ម្យ៉ាងទៀត យើងនឹងបង្រៀនដីវភាសាដល់សិស្ស ដូចធម្មតា ។ វិទ្យាស្ថានដីវភាសា នឹងជួយបន្ថែមវិជ្ជាខាងភាសាបរទេសដល់សិស្សយើង ។

ឧបសគ្គទី៤: គេថា កាលណាខ្មែររៀនជាខ្មែរ សិស្សខ្មែរ

មិនអាចបន្តវិជ្ជាទៅ ឧត្តមសិក្សាបានទេ ។

ការដោះស្រាយ : តាមផែនការ យើងនឹងធ្វើខេមរនីយកម្ម នៅឧត្តមសិក្សាទៀត ។ ដូច្នេះ សិស្សខ្មែរនឹងអាចបន្តវិជ្ជាពីមធ្យមសិក្សាទៅបានដោយងាយ ។

ឧបសគ្គទី៥: គេថា ការរៀនជាខ្មែរ នាំឲ្យសិស្សខ្មែរមិនចេះភាសាបរទេស ដែលជាបង្អួចមើលទៅក្រៅ ។

ការដោះស្រាយ: ការធ្វើឲ្យសិស្សខ្មែររៀនវិជ្ជាអ្វីៗជាខ្មែរ មិនមែនបានសេចក្តីថាឈប់ឲ្យខ្មែររៀនភាសាបរទេស មានភាសាបារាំងនឹងអង់អគ្លេសជាដើមនោះឡើយ ។ សិស្សខ្មែរនៅតែរៀនភាសាបរទេសដដែល ប៉ុន្តែ ក្នុងឋានៈជាជីវភាសា ។ យើងមានវិទ្យាស្ថានជីវភាសាមួយទៀត សំរាប់ឲ្យសិស្សខ្មែររៀនភាសាបរទេស ឲ្យបានជ្រៅជ្រះ ។

ម៉្យាងទៀត កាលណាសិស្សរៀនតាមភាសាខ្មែរ សិស្សនឹងរៀនឆាប់យល់ ឆាប់ចាំ ឆាប់ចេះ ជាហេតុនាំឲ្យសិស្សមានពេលទំនេរច្រើនសំរាប់រៀនជីវភាសា ។ ដូចនេះ សិស្ស

ខ្មែរនឹងរិតតែពូកែខាងជើវភាសាជាតុំខាន ។

**ឧបសគ្គទី៦**: គេថា ខេមរនីយកម្មក្នុងការសិក្សា នាំឲ្យសិស្សខ្មែរ មិនអាចទៅជាបុគ្គលិក ដែលអាចទៅចូលរួមធ្វើសន្និសីទអន្តរជាតិបាន ។

**ការដោះស្រាយ** : (ដូចការដោះស្រាយឧបសគ្គទី ៥)

រួមសេចក្ដីមក យើងឃើញថា យើងអាចដោះស្រាយគ្រប់បញ្ហាដែលជាឧបសគ្គជំទាស់ នឹងខេមរនីយកម្មក្នុងការសិក្សាបានទាំងអស់ ។

## វិធីអនុវត្តខេមរនីយកម្មក្នុងការសិក្សា

យើងអនុវត្តខេមរនីយកម្មក្នុងការសិក្សាតាមវិធីដូចតទៅ

១. វិធីធ្វើខេមរនីយកម្ម ទាំងក្នុងបឋមសិក្សា ទាំងក្នុងមធ្យមសិក្សា ទាំងក្នុងឧត្តមសិក្សា ( គណៈកម្មការធម្មវិជ្ជានីមួយៗ នឹងគណៈកម្មការវប្បធម៌ ធានាដោះស្រាយ) ។

២. វិធីធ្វើខេមរនីយកម្មក្នុងការសិក្សាបន្តិចម្តងៗទៅតាម សភាពការណ៍ ក្រសួងអប់រំជាតិ និងសង្គមជាតិ ។

៣. យើងនឹងអនុវត្តខេមរនីយកម្ម ក្នុងការសិក្សានេះ នៅមធ្យមសិក្សា នៅថ្នាក់ទី ៦ ទំនើប ចាប់តាំងពីឆ្នាំសិក្សា ១៩៦៧-៦៨ ទៅតាមតារាងខាងក្រោយនេះ ។

## តារាងវិធីអនុវត្តខេមរនីយកម្មក្នុងការសិក្សានៅថ្នាក់ទី ៦ និងទី ៥

| ថ្នាក់ | ឆ្នាំ | ប្រវត្តិនិង ភូមិវិទ្យា | គណិត វិទ្យា | រូបនិងគី មីវិទ្យា | ធម្មជាតិ វិទ្យា | សាស្ត្រាចារ្យ បារាំង | សាស្ត្រាចារ្យខ្មែរ |
|---|---|---|---|---|---|---|---|
| ទី ៦ | 1967-68 | ១ម៉ មួយសប្តាហ៍ | ៤ម៉ោង | សូន្យ | ២ម៉ោង | គ្មាន | មាន |
| ទី ៥ | 1968-69 | ១ម៉ មួយសប្តាហ៍ | ៤ ម៉. | ១ ម៉. | ២ ម៉. | ៧ នាក់ | មានចំនួនល្មមជំនួសបាន |

យើងមានសាស្ត្រាចារ្យសំរាប់មធ្យមសិក្សា ចំនួន
១.៤៧៩ នាក់ហើយ ។ យើងឃើញថាចំពោះខេមរនីយកម្មនៅ
ថ្នាក់ទី៦និងទី៥ ក្នុងសម័យបច្ចុប្បន្ននេះ បញ្ហាខ្វះសាស្ត្រាចារ្យ
ពុំចោទទេ ។ ចំពោះសៀវភៅ យើងនឹងអនុវត្តវិធីបង្រៀន
ផង តែងសៀវភៅផង ។ គណៈកម្មការបច្ចេកទេសខេមរ
នីយកម្មនឹងផ្តល់ពាក្យគន្លឹះ ដល់សាស្ត្រាចារ្យអ្នកអនុវត្តខេមរ
នីយកម្មនៅដើមឆ្នាំសិក្សា ដើម្បីឲ្យមានឯកភាពក្នុងការធ្វើ
មេរៀនជាខ្មែរ ។ ក្នុងរយៈពេលមួយខែមុន ឬបីខែមុន
គណៈកម្មការបច្ចេកទេសខេមរនីយកម្ម នឹងសុំយកមេរៀន
នោះពីសាស្ត្រាចារ្យជំនាញៗ មកពិនិត្យសំអិតសំអាង ដើម្បី
បង្ក្រងជាសៀវភៅទុកជាសៀវភៅពជការ ។ ចំពោះពាក្យ
គន្លឹះ យើងនឹងប្រែតាមពាក្យមន-ខ្មែរ ។ ប្រសិនបើមានការចាំ
បាច់ យើងនឹងទុកជាបារាំង ឬប្រែតាមពាក្យបាលីសំស្ក្រឹត ។

៤. នៅឆ្នាំសិក្សា ១៩៧៤–៧៥ យើងនឹងអនុវត្តខេមរ
នីយកម្មនៅឧត្តមសិក្សាតទៅទៀត ។

នៅពេលដែលយើងអនុវត្តខេមរនិយកម្មនៅមធ្យមសិក្សា ក្រសួងអប់រំជាតិរៀបចំរកសាស្ត្រាចារ្យនិងសៀវភៅ ទុកបំរុងសំរាប់ការអនុវត្តន៍ខេមរនិយកម្មនេះ នៅឧត្តមសិក្សាក្នុងឆ្នាំ ១៩៧៤-៧៥ ។ ចាប់តាំងពីឆ្នាំ ១៩៦៧ ដល់ឆ្នាំ ១៩៧៤ យើងមានរយៈពេលគ្រប់គ្រាន់ល្មមហ្វឹកហ្វឺនសាស្ត្រាចារ្យ និងសរសេរសៀវភៅសំរាប់ឧត្តមសិក្សាជាខ្មែរបាន ។

សេចក្តីសង្កេត

នៅបឋមសិក្សា សិស្សរៀនអ្វីជាខ្មែរអស់ទៅហើយ ។ យើងគ្រាន់តែឈប់លែងឲ្យសិស្សប្រឡងឡើងថ្នាក់ទី ៦ ទំនើប ដោយធ្វើចំណោទជាបារាំងទៅ ក៏ឃើញថាគ្រប់គ្រាន់ទៅហើយ ។

## សេចក្តីសំរេចចិត្ត

បន្ទាប់ពីការសិក្សាបញ្ហាខេមរនិយកម្មដោយហ្មត់ចត់មក គណៈកម្មការរៀបចំនិងអនុវត្តខេមរនិយកម្ម សូមសំរេចចិត្តដូចតទៅនេះ

១. តាមស្ថានភាពបច្ចុប្បន្នគួរធ្វើខេមរនីយកម្ម ។

២. ដើម្បីញុំាងខេមរនីយកម្មនេះ ឲ្យប្រព្រឹត្តទៅប្រកបដោយជោគជ័យ គួរគប្បីធ្វើបន្តិចម្តងៗ តាំងពីបឋមសិក្សា មធ្យមសិក្សា រហូតដល់ឧត្តមសិក្សា ។

៣. គួរចាប់ផ្តើមធ្វើខេមរនីយកម្មនេះ ចាប់ពីថ្នាក់ទី៦ទៅ នៅឆ្នាំសិក្សា ១៩៦៧–៦៨ ។

៤. នឹងសំរេចខេមរនីយកម្មតាមផែនការនេះកើតដោយ សុំឲ្យប្រជាពលរដ្ឋខ្មែរ ហើយជាពិសេសបុគ្គលិកសិក្សាខ្មែរ ទាំងអស់ ជួយឧបត្ថម្ភខាងផ្លូវចិត្ត ខាងផ្លូវកាយ និងសម្ភារៈ ដើម្បីជំរុញខេមរនីយកម្មឲ្យបានសំរេចដោយជោគជ័យ ក្នុងការដង្ហែតាមព្រះរាជនយោបាយ ឯករាជ្យជាតិ អព្យាក្រឹតភាព បង្រួបបង្រួមជាតិ អ្នកជាតិនិយម សង្គមនិយមព្រះពុទ្ធសាសនា សាម្គេចឌ់ ។

យើងលែងនិយមប្រើពាក្យបរទេសលាយបំរុះ
នឹងពាក្យខ្មែរ បើពាក្យនោះខ្មែរយើងមានហើយ ។

ការនេះ ដំបូងពិបាកបន្តិច មកពីទំលាប់ចាស់ ។
ប៉ុន្តែ បើយើងយល់ហើយខំ យើងប្រាកដជាធ្វើបាន ។

# កំណត់ហេតុ ៖

## កំណត់ហេតុ

នៃការប្រជុំរបស់គណៈមេប្រយោគ

នៃបណ្ឌិតវិជ្ជាអក្សរសាស្ត្រ ចំពោះស្នាព្រះហស្ត

**សម្តេចព្រះមហាសុមេធាធិបតី**

ជួន ណាត ជោតញ្ញាណោ

ព្រះសង្ឃរាជ

*ឆ្នាំ មួយពាន់ប្រាំបួនរយហុកសិបប្រាំពីរ ខែមេសា ថ្ងៃទីប្រាំពីរ ម៉ោងប្រាំបី នៅសាកលវិទ្យាធិការដ្ឋាន នៃសាកលវិទ្យាល័យភូមិន្ទ គណៈមេប្រយោគដែលបានត្រូវតែងតាំងឡើង*

ដោយអនុលោមតាមព្រះរាជយោបល់ដ៏ខ្ពង់ខ្ពស់នៃសម្ដេចព្រះប្រមុខរដ្ឋ ព្រះបិតាសិក្សាធិការជាតិ ដោយសេចក្ដីសំរេចនៃសាកលវិទ្យាធិការ លេខ ៤.៦១៩ ស.ស.ក. ចុះថ្ងៃទី ៩ ធ្នូ ឆ្នាំ ១៩៦៦ បានប្រជុំគ្នាជាលើកក្រោយបំផុត ដើម្បីពិភាក្សាអំពីទស្សនកថា បុនិក្ខេបបទសំរាប់បណ្ឌិតវិជ្ជាអក្សរសាស្ត្រ ចំពោះស្នាព្រះហស្តសម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត ជោតញាណោ ព្រះសង្ឃរាជ ។

បានមកកាន់ទីប្រជុំនោះ

- សហជីវិន កឹង-គុន សាកលវិទ្យាធិការ . . . ប្រធាន
- សហជីវិន ដួង-សារិន ព្រឹទ្ធសាស្ត្រាចារ្យនៃមហាវិទ្យាល័យអក្សរសាស្ត្រ . . . . . . . សមាជិក
- សហជីវិនកេង-វ៉ាន់សាក់ សាស្ត្រាចារ្យនៅមហាវិទ្យាល័យ អក្សរសាស្ត្រនិងមនុស្សសាស្ត្រ ... សមាជិក
- សហជីវិន ញ៉ុក-ថែម សាស្ត្រាចារ្យនៅមហាវិទ្យាល័យ អក្សរសាស្ត្រនិងមនុស្សសាស្ត្រ ... សមាជិក

គណៈមេប្រយោគខាងលើនេះបានពិនិត្យដោយហ្មត់ចត់នូវស្នាព្រះហស្តទាំងឡាយរបស់សម្តេចព្រះមហាសុមេធាធិបតីព្រះសង្ឃរាជ កាលពីពេលមុនរួចទៅហើយ ទើបយកការពិនិត្យនោះមកពិភាក្សាគ្នា អស់ថិរៈវេលាជំយូរ ក៏បានសំរេចជាឯកច្ឆន្ទដូចតទៅនេះ

ក្រៅអំពីអត្ថបទផ្នែកសាសនា ដែលមានសារៈជ្រាលជ្រៅផុតហួសសមត្ថភាពសមាជិកគណៈមេប្រយោគនេះ ទៅ ទៀត ហើយដែលជាស្នាព្រះហស្តមួយផ្នែកយ៉ាងសំខាន់ អាចបង្ហាញបំណេះវិជ្ជា នឹងប្រាជ្ញាទូលំទូលាយក្រៃលែងរបស់សម្តេចព្រះសង្ឃរាជ នៅមានស្នាព្រះហស្តជាអត្ថបទអក្សរសាស្ត្រថែមទៀតផង ពិសេសជាងគេគឺ :

— វចនានុក្រមខ្មែរ

— ហើយនឹងកច្ចាយនូបត្ថម្ភក: ដែលជាវេយ្យាករណ៍បាលី សរសេរនឹងពន្យល់ជាភាសាខ្មែរ ។

អត្ថបទទាំងពីរនេះ មិនត្រឹមតែមានលក្ខណៈជាស្នាដៃ

ឃ្លាំងវិជ្ជាប៉ុណ្ណោះទេ ថែមទាំងមានលក្ខណៈជា ទស្សនកថា ឬនិក្ខេបបទពិតប្រាកដ ព្រោះថាជាការតែងនិពន្ធ ដែលបិតនៅលើការបញ្ជាក់ទស្សនៈមួយដ៏សំខាន់ ។

ទស្សនកថា នៅក្នុងវចនានុក្រមខ្មែរ គឺសេចក្ដីបញ្ជាក់ទស្សនៈជាគិសត្ថនិយមដែលសរសេរ ទឹងពន្យល់ពាក្យដោយគោរព ជាតិសត្ថ ជាតិកំណើតរបស់ពាក្យ ។

កង្កត្វាយនូបត្ថម្ភកៈ ដែលជាវេយ្យាករណ៍បាលី សរសេរទឹងពន្យល់ជាភាសាខ្មែរ ទស្សនកថាជ្រាលជ្រៅ គឺសេចក្ដីបញ្ជាក់ទស្សនៈមូលដ្ឋាន ដែលនិយមថា ភាសាខ្មែរមានសមត្ថភាពអាចយកវិជ្ជាដ៏ពិបាកមកអធិប្បាយសិក្សាបានដោយច្បាស់លាស់ ។

យ៉ាងណាមិញ សម្ដេចព្រះសង្ឃរាជទ្រង់បានចាប់ផ្ដើមដំបូងបង្អស់យកមុខវិជ្ជាមួយផ្នែក ដែលយើងធ្លាប់ទទួលថាជាវិជ្ជាពិបាក ពោលគឺភាសាបាលីមកតែងនិពន្ធ ពន្យល់បង្រៀន

ជាភាសាជាតិ ឲ្យបានស្ទុះសាយទូទៅ ឆាប់យល់និងឆាប់ចេះ ។

ស្នាព្រះហស្ត ដែលអាចយកភាសាខ្មែរមកប្រើឲ្យបានសំរេចជោគជ័យបែបនេះបាន គឺពិតជាទស្សនកថាសំខាន់ណាស់ចំពោះការសិក្សាជាភាសាបរទេស ឬមួយជាភាសាជាតិពិសេស គឺចំពោះវិជ្ជាបាលី ដែលដើមឡើយ គេធ្លាប់តែទៅស្វែងរៀនឯបរទេស ឬរៀនជាភាសាបរទេសសុទ្ធ ៗ ។

ជោគជ័យក្នុងការប្រើភាសាខ្មែរនេះបានបំបាត់ទស្សនៈមួយ ដែលធ្លាប់ស្មានថា ភាសាជាតិពុំអាចបណ្តុះចំណេះចេះដឹងឡើយ ។

កច្ចាយនូបត្ថម្ភក:នេះបញ្ជាក់តាមទ្រឹស្តីផង និងតាមការអនុវត្តផងថា ភាសាខ្មែរពុំមែនខ្សត់ខ្សោយ ដូចទំលាប់ស្មាននោះទេ តែជាភាសារបស់ជនជាតិអ្នកមានអំបូរធ្លាប់រុងរឿង បានបញ្ចាំងអរិយធម៌ខ្ពង់ខ្ពស់រួចទៅហើយ ហើយជាភាសាមានសមត្ថភាពចំរើន អាចបណ្តុះបញ្ញា នឹងវិជ្ជាតទៅទៀត

បាន ។

ភាសាខ្មែរប្រើបានត្រឹមត្រូវក៏អាស្រ័យនៅលើវចនានុក្រមខ្មែរនោះដែរ ។

តើវចនានុក្រមនឹងអាងលើគោលអ្វី ដើម្បីពន្យល់នឹងសរសេរពាក្យឲ្យមានឯកភាពរបៀបរៀបរយ សមហេតុសមផលទៅតាមភាសាជាតិ ?

បញ្ហានេះ វចនានុក្រមខ្មែរបានដោះស្រាយដោយអាងលើទស្សនៈជាតិសព្ទនិយម ដែលពន្យល់ សរសេរ ហើយនឹងអានពាក្យតាមតួអក្សរជាតិ ប្រភពដើមរបស់ពាក្យ ។

គោលលំនាំនេះបានបង្កើតអក្សរជាតិសព្ទ ដែលតម្រូវឲ្យពាក្យណាមានជាតិជាខ្មែរសុទ្ធ ត្រូវសរសេរជាមួយនឹងអក្សរដើមកំណើតតាមវិធីបែបខ្មែរ ។ ចំណែកឯពាក្យមានជាតិប្រភពសំស្រ្កឹត-បាលីវិញ ត្រូវសរសេរជាមួយនឹងតួអក្សរដើមកំណើតតាមវិធីបែប សំស្រ្កឹត-បាលី ។

ទស្សនៈគោរពជាតិសព្ទ ផ្ទុយគ្នានឹងសូរសព្ទនិយម

ដែលយកសូរសំលេងធ្វើជាធំ : សូរយ៉ាងណាសរសេរយ៉ាងនោះ ។ អក្សរសរសេរតាមសំលេងមានឬនិយាយ ជាអក្សរសូរសព្ទ ។

កាលមុនសម័យវចនានុក្រមខ្មែរ អក្សរខ្មែរបានប្រើលាយចំរុះគ្នា នូវអក្សរសូរសព្ទផង និងអក្សរ ជាតិសព្ទផង ប៉ុន្តែពុំសមហេតុសមផលទេ ពីព្រោះជួនកាលក៏ជាអក្សរសូរសព្ទខ្លាំងពេក នាំឲ្យបាត់បង់ប្រភពពាក្យ ឬ ជួនកាលក៏ជាជាតិសព្ទហួសហេតុ នាំឲ្យពាក្យខ្មែរប្រែទៅជាពាក្យបរទេសវិញ ។

នៅក្នុងបរិយាសកាត់កយបែបនេះ វចនានុក្រមខ្មែរ ( ថ្មីព្រះហស្តសម្តេចព្រះសង្ឃរាជ ) បានរៀបអក្សរខ្មែរជារបៀបសង្កត់លើគោលជាតិសព្ទនិយម ដែលទ្រទ្រង់ឯកភាពនៃអក្ខរៈវិធីសព្វថ្ងៃនេះឯង ។

ឯអក្ខរៈវិធីគោរពជាតិសព្ទ ប្រភពខ្មែរ ឬប្រភពសំស្ក្រឹតបាលីបែបនេះបានធ្វើឲ្យវចនានុក្រមខ្មែរ មានសភាពជាគា

ពង យ៉ាងធំបង្ហាញពាក្យបរទេសហើយនឹងពាក្យខ្មែរ ដូចនេះ គឺមានលក្ខណៈជាទស្សនកថាពន្យល់អំពីប្រកតហើយនឹងតំលៃនៃអរិយធម៌ខ្មែរថែមទៀតផង ។

គឺការបេះបញ្ជាក់ទស្សនៈមូលដ្ឋានឲ្យទៅជាការអនុវត្ត បង្កើតឯកភាពក្បួនវិធីភាសា ដើម្បីយកភាសារៀបរយនេះទៅប្រើអធិប្បាយវិជ្ជាបែបដូចនេះហើយ ដែលជាហេតុនាំឲ្យស្នាព្រះហស្តសម្តេចព្រះសង្ឃរាជ មានលក្ខណៈជាទស្សនកថាពិតប្រាកដ សំរាប់បណ្ឌិតជាអក្សរសាស្ត្រ ។

ប៉ុន្តែទស្សនកថា នៅក្នុងវចនានុក្រមខ្មែរ ហើយនឹងកច្ចាយនូបត្ថម្ភកៈ ទាំងពីរនេះ ពុំមែនដាច់ចេញទីទៃពីគ្នាទេ ផ្ទុយទៅវិញ អាចរួមគ្នាជាទស្សនកថាធំមួយ ដែលបានបញ្ជាក់ថាភាសាខ្មែរគឺពិតជាគ្រឿងប្រដាប់បញ្ញា អាចអធិប្បាយវិជ្ជាបានតាមក្បួនវិធីច្បាស់លាស់ ។

តំលៃសំខាន់បំផុតបិតនៅលើចំណុច ដែលទស្សនកថា

ដ៏ធំសំបើមនេះ ពុំមែនត្រឹមតែជាសេចក្ដីបញ្ជាក់តាមផ្លូវទ្រឹស្ដីប៉ុណ្ណោះទេ ថែមទាំងជាការបញ្ជាក់តាមផ្លូវអនុវត្តប្រាកដជាក់ស្ដែង ធ្វើឱ្យអត្ថបទអក្សរសាស្ត្រ ឬព្រះហស្តទាំងពីរនេះមានសារៈជាគម្ពីរឯកសារមូលដ្ឋានសំរាប់ប្រើជាភាសាជាតិព្រមទាំងជាពន្លឺជួយបំភ្លឺវប្បធម៌អរិយធម៌ខ្មែរឱ្យភ្ញាក់ស្មារតីចំពោះសភាពនឹងតំលៃពិសេសរបស់ខ្លួនទៀតផង ។

អាស្រ័យហេតុផលទាំងប៉ុន្មានខាងលើនេះគណៈមេប្រយោគដែលបានតែងតាំងឡើងតាមព្រះរាជបញ្ញាដ៏ខ្ពង់ខ្ពស់ នៃសម្ដេចសហជីវិនព្រះប្រមុខរដ្ឋ បានមូលមាត់ទទួលជាឯកច្ឆន្ទថា :

“ស្នាព្រះហស្តសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ ក្នុងផ្នែកអក្សរសាស្ត្រមានលក្ខណៈពិតប្រាកដ ហើយនឹងតំលៃលើសលុប ជាទស្សនកថាបណ្ឌិតវិជ្ជាអក្សរសាស្ត្រ” ។

ដូចនេះសម្ដេចព្រះសុមេធាធិបតីព្រះសង្ឃរាជ ជួន-ណាតជោតញ្ញាណោ មានគុណធម៌ពេញលក្ខណៈជា មហាបណ្ឌិត

អក្សរសាស្ត្រ ។

គណៈមេប្រយោគ សូមថ្លែងសេចក្ដីសរសើរដ៏ក្រៃលែង ចំពោះ ព្រះមហាបណ្ឌិតអក្សរសាស្ត្រខ្មែរ ជាដំបូងបង្អស់នេះ ហើយសូមថ្លែងដ៏ឧឡារិកថា:

វប្បធម៌ខ្មែរអាចមានជោគជ័យបែបនេះបាន ក៏ដោយសារ ព្រះរាជនយោបាយសម្ដេចសហជីវិន ព្រះប្រមុខរដ្ឋ ។ ព្រះអង្គ បានទាមទារឯករាជ្យជាតិបាន ហើយក៏ទ្រង់បានសាងជាតិគ្រប់ វិស័យ ដើម្បីលើកដកើងវប្បធម៌ អរិយធម៌ ហើយទង់កិត្តិយស ខ្មែរ ឲ្យបានរុងរឿងតាមគំណាដំណែលដ៏ល្បីល្បាញ នៃ ព្រះរាជបល្ល័ង្កក្នុងប្រវត្តិសាស្ត្រខ្មែរ ។

ធ្វើនៅសាកលវិទ្យាធិការដ្ឋាន នៃសាកលវិទ្យាល័យភូមិន្ទ

ក្រុងភ្នំពេញ នៅថ្ងៃទី៣ មេសា ១៩៦៣

# ដកស្រង់ពាក្យដែលប្រែហើយ

## ខាងរូបវិទ្យា-គីមីវិទ្យា PHYSIQUE-CHIMIE

| | |
|---|---|
| l' horizontale | ខ្សែដេក |
| l' oblique | ខ្សែទ្រេត |
| la verticale | ខ្សែឈរ |
| la verticale en un point | ខ្សែឈរត្រង់ចំណុចមួយ |
| l' attraction terrestre ou la pesanteur | ទំនាញដី |
| orthogonal | រត់កែង |
| le centre de gravité | ទីប្រជុំទំងន់ |
| l' intensité | អាំងតង់ស៊ីតេ |
| le niveau de maçon | នីវ៉ូជាងកំបោរ |

le plan ប្លង់

l' équilibre stable លំនឹងស៊ប់

l' équilibre indifférent លំនឹងគ្រប់ទិស

l' étalon ខ្នត់គំរូ

la masse volumique ម៉ាស់មាឌ

## ខាងធម្មជាតិវិទ្យា SCIENCES NATURELLES

le membrane ភ្នាស

le mouvement រំពើក, ចលនា

le bimane សត្វដៃពីរ

le bipède សត្វជើងពីរ

le quadrumane សត្វជើងបួន

l' artère សរសៃបេញ

la veine សរសៃបួល

## ខាងគណិតវិទ្យា MATHEMATIQUES

| | |
|---|---|
| la conséquence | វិបាក |
| la donnée | បំរាប់ |
| la conclusion | សន្និដ្ឋាន |
| le point | ចំណុច |
| la ligne brisée | ខ្សែកាច់ |
| la ligne courbe | ខ្សែកោង |
| la ligne droite | ខ្សែត្រង់ ឬបន្ទាត់ |
| l'angle consécutif | មុំក |
| l'angle aigu | មុំស្រួច |
| l' angle droit | មុំកែង |
| l' angle obtu | មុំទាល |
| l' angle plat | មុំរាប |
| l' angle saillant | មុំលយ |

| | |
|---|---|
| l' angle rentrant | មុំផក |
| les angles adjacents | មុំជាប់ |
| les angles complémentaires | មុំផ្គុំកែង |
| les angles supplémentaires | មុំផ្គុំរាប |
| les angles opposés par le sommet | មុំទល់កំពូល |
| les angles alternes internes | មុំឆ្លាស់ក្នុង |
| les angles alternes externes | មុំឆ្លាស់ក្រៅ |
| se déplacer | ដើរ |

## ខាងសកម្មភាពប្រតិបត្តិ ACTIVITES PRATIQUES

| | |
|---|---|
| le câble | ខ្សែកាប |
| le raccordement | តំណ |
| la boucle | ក្រវិល |
| le fusible | ហ្វុយស៊ីប |
| la douille | ឌុយ |

le fer à souder électrique — ក្បាលមាន់

le schéma de principe — គំនូសគោល

## ភូមិវិទ្យា GEOGRAPHIE

l' isotherme — ខ្សែកំដៅ

l' isoyète — ខ្សែភ្លៀង

le cirrus — ពពកស្បៃ (សៀរុស)

le stratus — ពពកអន្ទាយ (ស្ត្រាទុស)

le cumulus — ពពកផ្កាស្ពៃ (គូមូលុស)

le nimbus — ពពកខ្មៅ (ណាំបុស)

la masse d'air — ម៉ាស់ខ្យល់

la condensation — បណ្តុំចំហាយ

l' humidité — សំណើម

le front — ព្រំខ្យល់

la grêle — ព្រឹល

le givre — សន្សើមកក